ដំណើររឿងប្រព័ន្ធផ្សព្វផ្សាយ
ដើម្បីផ្លាស់ប្តូរការរើសអើង
ប្រកាន់ភេទនិងគំរូភេទ

# កិច្ចការផ្ទះជាការងាររួម

(Việc nhà là của chung)

*រួមចែករំលែក រួមជឿនលឿន រួមសុភមង្គល*

Hoàng Đức & Edlab



BÌNH ĐẲNG GIỚI
VÙNG DÂN TỘC THIỂU SỐ & MIỀN NÚI
CHƯƠNG TRÌNH MỤC TIÊU QUỐC GIA DTTS & MN

NHÀ XUẤT BẢN
PHỤ NỮ VIỆT NAM

# កិច្ចការផ្ទះជាការងាររួម

*រួមចែករំលែក រួមជឿនលឿន រួមសុភមង្គល*

Hoàng Đức & Edlab

អ្នកបកប្រែ៖ Kiêm Hạnh



NHÀ XUẤT BẢN PHỤ NỮ VIỆT NAM

# អារម្ភកថា

កម្មវិធីគោលដៅជាតិអភិវឌ្ឍសេដ្ឋកិច្ច – សង្គមកិច្ចតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ ដែលបានអនុម័តដោយនាយករដ្ឋមន្ត្រីតាមសេចក្តីសម្រេចលេខ១៧១៩/QĐ-TTg ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ មានសរុប១០គម្រោងសមាសភាព។ ក្នុងនោះ សមាគមសម្ព័ន្ធនារីវៀតណាមដឹកនាំគម្រោងទី៨៖ *"អនុវត្តសមភាពភេទនៅតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ"*។

ដោយមានគោលបំណង "បង្កើនការយល់ដឹង ផ្លាស់ប្តូរការរើសអើងប្រកាន់ភេទ ថែរក្សានិងដោះស្រាយបញ្ហាបន្ទាន់សម្រាប់ស្ត្រីនិងកុមារ"។ គម្រោងទី៨នេះរួមមាន៤ខ្លឹមសារ ជ្រៀតជ្រែកជាមួយសកម្មភាពចម្បង៖

- ផ្សព្វផ្សាយ ឃោសនាផ្លាស់ប្តូរ "ផ្នត់គំនិត របៀបធ្វើ" រួមចំណែកការលុបចោលបណ្តាការរើសអើងប្រកាន់ភេទនិងគំរូភេទក្នុងគ្រួសារនិងសហគមន៍ ជាមួយនឹងទំនៀមទម្លាប់អាក្រក់និងបញ្ហាសង្គមបន្ទាន់សម្រាប់ស្ត្រីនិងកុមារ។

- កសាងនិងពង្រីកបណ្តាគំរូផ្លាស់ប្តូរ "ផ្នត់គំនិត របៀបធ្វើ" លើកកម្ពស់អំណាចសេដ្ឋកិច្ចសម្រាប់ស្ត្រីនិងជំរុញសមភាពភេទ និងដោះស្រាយបញ្ហាបន្ទាន់សម្រាប់ស្ត្រីនិងកុមារ។

- ធានាសិទ្ធិឱ្យស្ត្រីនិងកុមារមានសិទ្ធិនិយាយ និងចូលរួមយ៉ាងពិសេសក្នុងសកម្មភាពអភិវឌ្ឍសេដ្ឋកិច្ច – សង្គមកិច្ចរបស់សហគមន៍ ត្រួតពិនិត្យនិងការផ្តល់យោបល់ជំនួយស្ត្រីចូលរួមគ្រប់គ្រងដឹកនាំក្នុងប្រព័ន្ធនយោបាយ។

- ផ្តល់ចំណេះដឹងអំពីសមភាពភេទ និងបំណិននៃការអនុវត្តដាក់បញ្ចូលភេទសម្រាប់កម្មាភិបាលមេភូមិ អ្នកមុខអ្នកការសាសនា និងអ្នកមានប្រជាប្រិយភាពនៅក្នុងសហគមន៍។

កម្រងសៀវភៅ *"ដំណើររឿងផ្សព្វផ្សាយផ្លាស់ប្តូរការរើសអើងប្រកាន់ភេទនិងគំរូភេទ"* ដែលជាផ្នែកមួយនៃគម្រោងទី៨ ត្រូវបានគ្រឹះស្ថានបោះពុម្ពផ្សាយនារីវៀតណាមចាត់តាំង រួមមានចំនួន ៤ក្បាល ដែលត្រូវបានសរសេរជាប្រភេទរឿងងាយស្រួលយល់ និងជិតស្និទ្ធជាមួយបណ្តាជនជាតិភាគតិចៈ

១. ***កិច្ចការផ្ទះជាការងាររួម*** – រួមគ្នាចែករំលែក រួមគ្នាជឿនលឿន រួមសុភមង្គល។

២. ***ប្អូនចង់បានទៅសាលា*** – កុមារានិងកុមារីសុទ្ធតែមានសិទ្ធិបានទៅរៀន។

៣. ***ផ្ទះពីរជំបូល*** – ស្ត្រីអាចធ្វើសេដ្ឋកិច្ច រួមកសាងគ្រួសារសុខដុមរមនា ជឿនលឿនសុភមង្គល។

៤. ***ការពិតយើងក៏អាចធ្វើបានដែរ*** – មនុស្សគ្រប់គ្នាសុទ្ធតែមានសក្តានុពល ភាពខ្លាំងដើម្បីសិក្សា ជោគជ័យនិងសុភមង្គល។

នេះជាកម្រងសៀវភៅសម្រាប់ជំនួយស្ត្រីនិងកុមារ កម្មាភិបាលនៅមូលដ្ឋាននិយាយរួម ក្នុងនោះមានកម្មាភិបាលសមាគមនារី បានផ្សព្វផ្សាយដ៏ល្អបណ្តាខ្លឹមសារឃោសនា "អនុវត្តសមភាពភេទនៅតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ"។

សង្ឃឹមថាកម្រងសៀវភៅនេះអាចនឹងរួមចំណែកផ្លាស់ប្តូរនូវទំនៀមទម្លាប់ហួសសម័យ ទំនៀមទម្លាប់ឱនថយ។ ទន្ទឹមនោះ លើកទឹកចិត្ត ពង្រីកនូវតម្លៃជឿនលឿនសម្រាប់ឱ្យស្ត្រីនិងកុមារនៅតំបន់ជនជាតិភាគតិចនិងតំបន់ភ្នំ។

សូមឧទ្ទេសនាមជូនមិត្តអ្នកអាន។

**គ្រឹះស្ថានបោះពុម្ពផ្សាយនារីវៀតណាម**

*✶កំណត់សម្គាល់៖ រូបភាពសំលៀកបំពាក់នៅក្នុងសៀវភៅគ្រាន់តែមានលក្ខណៈជាតួសម្តែងប៉ុណ្ណោះ។*







ធ្វើដូចម្ដេចដើម្បីរក្សាបានភាពកក់ក្ដៅ
នៃសុភមង្គលក្នុងគ្រួសារ?

*“ ប្ដីប្រពន្ធរួមជួយគ្នារាល់កិច្ចការ*
*ធ្វើអ្វីក៏បានសម្រេច។ ”*

*– សុភាសិតជនជាតិតៃ*

សេះសមុទ្រជាប្រភេទសត្វត្រីដែលរស់ជាគូ។
ប៉ុន្តែសេះសមុទ្រញីវិញ មិនមានផ្ទៃពោះទេ។
បន្ទាប់ពីសេះសមុទ្រញីពងក្នុងថង់ភ្នាស់
របស់សេះសមុទ្រឈ្មោល សេះសមុទ្រឈ្មោល
នឹងមានផ្ទៃពោះរយៈពេលពីរដល់បីសប្តាហ៍។







សត្វល្អិតទឹកយក្ស

(GIANT WATER BUG)

## សត្វល្អិតទឹកយក្ស (Giant Water Bug)

នៅអាមេរិកខាងជើង សត្វល្អិតទឹកឈ្មោលមានផ្ទៃពោះ
ប្រហែល១៥០គ្រាប់លើខ្នង ហើយថែទាំវារយៈពេល៣សប្តាហ៍។
ពួកវាហាលខ្លួនខាងក្រៅកំដៅដើម្បីទប់ស្កាត់ការលូតលាស់នៃផ្សិត
និងការពារពូជឱ្យផុតពីគ្រោះថ្នាក់។





ស្វាតឿអាហ្វ្រិកខាងត្បូង

(ស្វា MARMOSET)



ស្វាឪពុកបីកូន សិតរោមនិងបំបៅចំណីឱ្យកូនភ្លាមៗ
បន្ទាប់ពីទើបកើតចេញ។ កូនស្វាតូចមួយអាចមានទម្ងន់
ដល់ទៅ ២៥% នៃទម្ងន់ស្វាម្ដាយ ដែលស្មើនឹងស្ត្រីមាន
ទម្ងន់៥៥គីឡូសម្រាលកូនមានទម្ងន់១៤គីឡូអីចឹង។
ហេតុនេះ ស្វាម្ដាយមានហានិភ័យនៃការស្លាប់ខ្ពស់
ក្នុងពេលសម្រាល។ ដូច្នេះ នៅពេល
ស្វាម្ដាយសម្រាលកូន ស្វាឪពុកនឹងជួយសម្អាត
ដោយការលិតជុំវិញរាងកាយស្វាម្ដាយ។

សត្វអូទ្រីសឈ្មោលក៏ខិតខំរក្សាភាពកក់ក្ដៅនៃសុភមង្គលដែរ។ សត្វអូទ្រីសឈ្មោលនឹងជួយជីករូងសម្រាប់ឱ្យសត្វអូទ្រីសមេពង ហើយភ្ញាស់ពងប្រហែល៥០ពងក្នុងរយៈពេល៦សប្ដាហ៍។ បន្ទាប់ពីពងញាស់ សត្វអូទ្រីសឈ្មោលក៏មានភារៈទាំងថៃទាំ និងការពារកូនផងដែរ។





# ចែករំលែកការងារផ្ទះ គ្រួសារសុភមង្គល!



កន្លាតស៊ីឈើ (SALGANEA TAIWANENSIS)

សត្វកន្លាតឈ្មោលស៊ីឈើ (Salganea Taiwanensis) ធ្វើសំបុកផង ថែមទាំងរកអាហារឱ្យកូនទៀត។ សត្វឈ្មោលទាំងនេះស្អាតបាតណាស់ តែងតែសម្អាតសំបុកយ៉ាងទៀងទាត់ ដើម្បីទប់ស្កាត់នូវការវាយប្រហារពីបណ្ដាផ្សិត។



សត្វអធិរាជភេនឃ្វីនឈ្មោល (Emperor Penguin) ក៏ខំប្រឹងថែរក្សាកូនអស់ពីសមត្ថភាព។ បន្ទាប់ពីភេនឃ្វីនញី ពងតែមួយប៉ុណ្ណោះ ភេនឃ្វីនឈ្មោលប្រើរាងកាយដើម្បីភ្ញាស់ពង រយៈពេល៤ខែ។ ក្នុងអំឡុងនោះ ភេនឃ្វីនញីនឹងទៅរកចំណីនៅសមុទ្រ ហើយយកមកចែករំលែកភេនឃ្វីនឈ្មោល និងភេនឃ្វីនកូន។



# អធិរាជភេនឃ្វីន (EMPEROR PENGUIN)



# មាន់ប្រូកាត (PTEROCLIDIDIA)



មាន់ប្រូកាតឈ្មោល ក៏ជាគំរូល្អមួយដែរ។ រាល់ពេលព្រឹក ពួកមាន់ប្រូកាតឈ្មោលទាំងនេះនឹងហើរទៅដល់បឹង ឬអាងទឹកជិតបំផុតហើយចុះត្រាំទឹក។ នៅពេលត្រឡប់មកសំបុក ហ្វូងមាន់ប្រូកាតកូនតូចៗនឹងផ្តុំគ្នាមកផឹកទឹក ដែលបានរក្សាទុកនៅក្នុងរោមជិតផ្ទៃពោះរបស់មាន់ឈ្មោល។



នៅក្នុងគ្រួសារយើងក៏អញ្ចឹងដែរ
ប្ដីប្រពន្ធត្រូវគោរពគ្នា  សមភាព ស្រឡាញ់
និងចែករំលែកគ្នាទៅវិញទៅមក។



*“ស្រឡាញ់ខ្លួនត្រូវស្ងួនចំណី ប្ដីប្រពន្ធ
ស្រឡាញ់គ្នាត្រូវចេះយោគយល់គ្នា។”*

*– សុភាសិតជនជាតិខ្មែរ*






រួមគ្នាចែករំលែក
ដើម្បីគ្រួសារបន្ថែមសុភមង្គល!


ប៉ុន្មានមេរៀនកំប៉ិកកំប៉ុកនេះ
កូនទៅសួរម្ដាយ!




ប្ដីប្រពន្ធមានភារកិច្ចស្មើគ្នាក្នុងការចិញ្ចឹមនិងប្រៀនប្រដៅកូន។

ប្តីប្រពន្ធមានភារកិច្ចស្មើគ្នារួមវិភាគទានហិរញ្ញវត្ថុគ្រួសារ។



*“ស្នេហាល្អគ្រាមួយដំណាក់កាល ប្តីប្រពន្ធល្អមួយជីវិត។”*

*– សុភាសិតជនជាតិម៉ុង*


ការចំណាយ
ប្រចាំថ្ងៃ
10%
វិនិយោគ
55%
ប្រិតសំចៃ
10%
អភិវឌ្ឍន៍
ខ្លួនឯង
5%
10%
សប្បុរសធម៌
10%
សោយសុខ



ប្តីប្រពន្ធជួយគ្នាដើម្បីលើកកំពស់សមត្ថភាពវិជ្ជាជីវៈ
កម្រិតចំណេះដឹង និងការចូលរួមក្នុងសកម្មភាពសង្គម។

*“រួមគ្នាចេញសេចក្តីសម្រេច
ការងារដែលធ្ងន់ក៏ធ្វើឱ្យស្រាល!”*



ប្ដីប្រពន្ធត្រូវចេះស្ដាប់គ្នា រួមគ្នាពិភាក្សា...



... ឯកភាពនិងសម្រេចលើបញ្ហារួមរបស់គ្រួសារ។



រិៈគន់ ស្ដីបន្ទោសដែលនាំឱ្យ
មនុស្សមានសុទិដ្ឋិនិយមបំផុតក៏ត្រូវតែព្រួយចិត្តដែរ។



ពាក្យលើកទឹកចិត្ត ការចែករំលែក
នឹងជួយរំសាយទុក្ខសោក!



# កិច្ចការផ្ទះ




ជាការចាររួម!

*Chịu trách nhiệm xuất bản:*
Giám đốc - Tổng biên tập
**Khúc Thị Hoa Phượng**

Biên tập: Nguyễn Thị Hòa Bình
Vũ Thị Phương
Bìa: Lộc Linh
Trình bày: Lộc Linh - Xuân Ngân
Sửa bản in: Anh Đào

**NHÀ XUẤT BẢN PHỤ NỮ VIỆT NAM**
39 Hàng Chuối - Hà Nội
ĐT: (024) 39717979 - 39717980 - 39716727 - 39712832
Fax: (024) 39712830
E-mai: nxbphunu.com.vn
Website: www.nxbphunu.com.vn

Chi nhánh:
16 Alexandre de Rhodes - Q1 - TP. Hồ Chí Minh
ĐT: (028) 38234806

---

**កិច្ចការផ្ទះជាការងាររួម**

(VIỆC NHÀ LÀ CỦA CHUNG) - TIẾNG KHMER